00172872

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

MOD/Nº D58

**Declassified to Public**
**06 September 2012**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2008
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាចាត់ឲ្យស៊ើបសួរជំនួស
# Rogatory Letter
# Commission Rogatoire

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥ (៥) និង វិធាន ៦២ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ

ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះ **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩**



ECCC * CETC CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដោយមិនអាចបំពេញកិច្ចដែលចាំបាច់ខាងក្រោមដោយខ្លួនឯងបាន

**ហេតុដូច្នេះ សម្រេច**

ផ្ទេរកិច្ចការនេះឱ្យទៅអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលរួមមាន លោក **ស៊ឹម សុវិយ៉ា** និង លោក Steve Heder ដែលត្រូវបំពេញកិច្ចជាក្រុមមួយ ឬ នៅក្នុងករណីចាំបាច់ និងមានការយល់ព្រមពីអ្នកស៊ើបអង្កេតម្នាក់ទៀតអាចបំពេញកិច្ចការនេះតែម្នាក់ឯង ដើម្បីចាត់ការស៊ើបសួរជំនួសតាមបេសកកម្មដែលមានភ្ជាប់មកជាមួយនឹងដីកានេះ។

កំណត់ហេតុបញ្ចាប់បេសកកម្ម រួមទាំងច្បាប់ថតចម្លងដោយមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមមួយច្បាប់ (រួមទាំងឯកសារ ឬភស្តុតាងឧបសម្ព័ន្ធទាំងអស់ផង) ត្រូវប្រគល់មកឱ្យយើងក្នុងរយៈពេល បី ខែគិតចាប់ពីថ្ងៃចុះហត្ថលេខាលើដីកាចាត់អោយស៊ើបសួរជំនួសនេះ ។

**បេសកកម្ម**

យើង បង្គាប់មកលោកដែលមានឈ្មោះខាងលើ:

១- ទំនាក់ទំនងជាមួយអ្នកទទួលខុសត្រូវនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង តាមរយៈមធ្យោបាយសមស្របដើម្បីស្នើអោយមជ្ឈមណ្ឌលនេះសហការក្នុងការពិនិត្យ និង/ឬ ថតចម្លងឯកសារណាមួយ បណ្ណាសារសោតទស្សន៍ ឬ ឯកសារផ្សេងទៀតទាក់ទងទៅនឹងការស៊ើបសួរខាងលើរបស់អង្គជំនុំជម្រះវិសាមញ្ញដែលកំពុងដំណើរការ ដែលស្ថាប័ននេះមាន។

២- ពិនិត្យឯកសារទាំងនោះនៅទីកន្លែង និង/ឬ ស្នើសុំអោយផ្តល់ជូននូវឯកសារថតចម្លងជាក្រដាសឬជាប្រព័ន្ធអេឡិចត្រូនិច ហើយប្រសិនបើចាំបាច់ត្រូវធ្វើការថតចម្លងឯកសារទាំងនោះ។

៣- ត្រូវបង្ហាញជូនលទ្ធផលដល់សហចៅក្រមស៊ើបអង្កេតជាប្រចាំនៅក្នុងកំឡុងពេលបេសកកម្មរបស់ខ្លួន ថាតើមានភស្តុតាងដោះបន្ទុក ឬ ភស្តុតាងដាក់បន្ទុកណាមួយដែលមាននៅក្នុងឯកសារដែលបានពិនិត្យ អាចយកមកពិចារណាដើម្បីដាក់ចូលនៅក្នុងសំណុំរឿង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

MARCEL Lemonde